# សេវាកម្មគ្រួសារ និងបុត្រធីតា

# កំណត់សម្គាល់អំពីការអនុវត្តភាពជាឯកជន

**កំណត់សម្គាល់នេះ បរិយាយពីវិធីដែលព័ត៌មានសុខភាពរបស់អ្នក អាចត្រូវបានប្រើប្រាស់ និងផ្សព្វផ្សាយ និងពីវិធីដែលអ្នកអាចទទួលបានព័ត៌មាននេះៗ សូមពិនិត្យមើលព័ត៌មាននេះ ឱ្យបានហ្មត់ចត់ឡើងវិញៗ ភាពជាឯកជនស្តីអំពីព័ត៌មានសុខភាពរបស់អ្នក គឺពិតជាមាន សារសំខាន់សម្រាប់យើងៗ**

## កាតព្វកិច្ចផ្នែកច្បាប់របស់យើង

យើងត្រូវបានតម្រូវដោយច្បាប់របស់សហព័ន្ធ និងរដ្ឋ ដើម្បីធានាពីភាពជាឯកជនស្តីអំពីព័តិមានសុខភាពរបស់លោកអ្នក។ ជាមួយគ្នានេះ យើងក៏ត្រូវបានតម្រូវឱ្យផ្តល់ជូនជាកំណត់សម្គាល់អំពីការអនុវត្តភាពជាឯកជន កាតព្វកិច្ចផ្នែកច្បាប់របស់យើង និងសិទ្ធិទាក់ទិននឹងព័តិមានសុខភាព របស់លោកអ្នក។ យើងត្រូវតែអនុវត្តទៅតាមការ អនុវត្តភាពជាឯកជន ដែលបានរៀបរាប់នៅក្នុងកំណត់សម្គាល់នេះ ខណៈពេល កំណត់សម្គាល់នេះ នៅមានសុពលភាព។ កំណត់សម្គាល់នេះមានប្រសិទ្ធភាពកាលពីថ្ងៃទី២ ខែតុលា ឆ្នាំ២០០៩ ហើយនឹងនៅតែមាន ប្រសិទ្ធិភាពរហូតដល់យើង ធ្វើការផ្លាស់ប្តូរវា។

យើងរក្សាសិទ្ធិដើម្បីធ្វើការផ្លាស់ប្តូរការអនុវត្តភាពជាឯកជនរបស់យើង ដ៏រាបណាការអនុវត្តនេះគោរពទៅតាមច្បាប់ ដែលមានចែងស្រាប់។ ប្រសិនបើ យើងធ្វើការពិនិត្យសារជាថ្មីលើព័តិមានណាមួយនៅក្នុងកំណត់សម្គាល់នេះ នោះយើង នឹងចេញផ្សាយអត្ថបទថតចម្លងនៃការអនុវត្ត ភាពជាឯកជនដែលត្រូវ បានពិនិត្យសារជាថ្មីនោះ នៅតាមការិយាល័យ និមួយៗរបស់យើង ដែលនឹងបញ្ជាក់ពីកាលបរិច្ឆេទដែលកំណត់សម្គាល់ ដែលត្រូវបានពិនិត្យសារជាថ្មី នេះមានប្រសិទ្ធិភាព។ យើងរក្សាសិទ្ធិដើម្បីធ្វើការផ្លាស់ប្តូរការអនុវត្តភាពជាឯកជន និងរយៈកាលថ្មីនៃ កំណត់សម្គាល់របស់យើងដែលមានប្រសិទ្ធិភាព សម្រាប់ព័តិមានសុខភាពទាំងអស់ដែលយើងបានរក្សាទុក រួមមានព័តិមានសុខភាពដែលយើង បានបង្កើតឡើង ឬដែលយើងបានទទួលមុននឹងយើង ធ្វើការផ្លាស់ប្តូរ។ លោកអ្នកអាចស្នើសុំអត្ថបទថតចម្លងនៃកំណត់សម្គាល់របស់យើង គ្រប់ពេលវេលាទាំងអស់។ សម្រាប់ព័តិមានបន្ថែម ទាក់ទិននឹងការអនុវត្តភាពជាឯកជន របស់យើង ឬសម្រាប់អត្ថបទថតចម្លង នៃកំណត់សម្គាល់នេះ សូមទាក់ទងមកកាន់ពួកយើងដោយប្រើប្រាស់ព័តិមាន ដែលមាននៅចុងបញ្ចប់នៃកំណត់សម្គាល់នេះ។

## ការប្រើប្រាស់ និងការផ្សព្វផ្សាយអំពីព័តិមានសុខភាព

យើងប្រើប្រាស់ និងផ្សព្វផ្សាយព័តិមានសុខភាពអំពីលោកអ្នក សម្រាប់ការព្យាបាល ការបង់ថ្លៃ និងប្រតិបត្តិការ ថែទាំសុខភាព។

ឧទាហរណ៏:

**ការព្យាបាលៈ** យើងអាចប្រើប្រាស់ ឬផ្សព្វផ្សាយព័តិមានសុខភាពរបស់លោកអ្នកទៅកាន់អ្នកជំនាញផ្នែកថ្នាំ ឬអ្នកផ្តល់សេវាកម្មថែទាំសុខភាព ដែលផ្តល់ការព្យាបាលដល់អ្នក។

**ការបង់ថ្លៃៈ** យើងអាចប្រើប្រាស់ និងផ្សព្វផ្សាយព័តិមានសុខភាពរបស់លោកអ្នក ដើម្បីទទួលបានការបង់ថ្លៃសម្រាប់សេវាកម្មដែលយើង ផ្តល់ឱ្យអ្នក។

**ប្រតិបត្តិការថែទាំសុខភាពៈ** យើងអាចប្រើប្រាស់ និងផ្សព្វផ្សាយព័តិមានសុខភាពដែលពាក់ព័ន្ធនឹងប្រតិបត្តិការ ថែទាំសុខភាពរបស់លោកអ្នក។ ប្រតិបត្តិការថែទាំសុខភាពរួមមានការវាយតម្លៃអំពីគុណភាព និងសកម្មភាព កែលម្អរនានា ដោយពិនិត្យសារឡើងវិញអំពីសមត្ថភាព និងគុណវុឌ្ឍិខាង វិជ្ជាជីវៈផ្នែកថែទាំសុខភាព ដោយ វាយតម្លៃការងាររបស់អ្នកអនុវត្ត និងអ្នកផ្តល់សេវាកម្ម ដោយអនុវត្តកម្មវិធីបំពាក់បំប៉ន ការទទួលស្គាល់ ការចេញលិខិតបញ្ជាក់ ការផ្តល់អាជ្ញាប័ណ្ណ និងការផ្តល់សិទ្ធិតំណាងសម្រាប់សកម្មភាពទាំងនោះ។

**ការអនុញ្ញាតរបស់លោកអ្នកៈ** លើសពីប្រើប្រាស់ព័តិមានសុខភាពរបស់អ្នកសម្រាប់ការព្យាបាល ការបង់ថ្លៃ ឬ ប្រតិបត្តិការថែទាំសុខភាព អ្នកអាច ផ្តល់ការអនុញ្ញាតជាលាយល័ក្ខអក្សរដើម្បីប្រើប្រាស់ព័តិមានសុខភាពរបស់អ្នក ឬ ដើម្បីផ្សព្វផ្សាយព័តិមាននោះទៅបុគ្គលណាម្នាក់ សម្រាប់គោលបំណង ផ្សេងៗ។ ប្រសិនលោកអ្នកផ្តល់អនុញ្ញាតមក យើងខ្ញុំ លោកអ្នកអាចបញ្ឈប់ការអនុញ្ញាតនេះនៅក្នុងអត្ថបទសរសេរ បានគ្រប់ពេលវេលាទាំងអស់។ ការបញ្ឈប់ការអនុញ្ញាតរបស់លោកអ្នកនឹងមិនធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់ ឬការផ្សព្វផ្សាយណាមួយ ដែលត្រូវបានអនុញ្ញាតតាមការអនុញ្ញាតរបស់អ្នក

ខណៈពេលដែលវាបានមានប្រសិទ្ធិភាពហើយនោះឡើយ។ ប្រសិនបើអ្នកមិនចេញជា សេចក្តីអនុញ្ញាតជាលាយល័ក្ខអក្សរនោះទេ នោះយើងមិនអាចប្រើប្រាស់ ឬផ្សព្វផ្សាយព័តិមានសុខភាព របស់លោកអ្នក ដោយមូលហេតុណា មួយឡើយ លើកលែងតែព័តិមានដែលបានរៀបរាប់នៅក្នុងកំណត់សម្គាល់នេះ។

**សម្រាប់ក្រុមគ្រួសារ និងមិត្តភ័ក្តិរបស់លោកអ្នកៈ** យើងត្រូវតែផ្សព្វផ្សាយព័តិមានសុខភាពរបស់លោកអ្នកទៅកាន់លោកអ្នក ដូចដែលបានរៀបរាប់នៅក្នុងផ្នែកសិទ្ធិរបស់អ្នកជំងឺ (Patient Rights) នៅក្នុងកំណត់សម្គាល់នេះ។ យើងអាចផ្សព្វផ្សាយព័តិមាន សុខភាពរបស់លោកអ្នកទៅកាន់សមាជិកគ្រួសារ មិត្តភ័ក្តិ ឬនរណាម្នាក់ដើម្បីជាសារប្រយោជន៍បន្ថែមទៀតក្នុងការជួយដល់ការថែទាំសុខភាព ឬការបង់ថ្លៃសម្រាប់ការថែទាំសុខភាពរបស់លោកអ្នក ប៉ុន្តែលុះត្រាតែអ្នកយល់ព្រមថាយើងអាចធ្វើដូច្នេះបាន។

**បុគ្គលដែលចូលរួមពាក់ព័ន្ធក្នុងការថែទាំសុខភាពៈ** យើងអាចប្រើប្រាស់ ឬផ្សព្វផ្សាយព័តិមានសុខភាពដើម្បីជូន ជាដំណឹង ឬជួយដល់ការផ្តល់ដំណឹង (រួមទាំងការគូសបញ្ជាក់ ឬទីកន្លែង) របស់សមាជិកគ្រួសារ អ្នកតំណាងផ្ទាល់ខ្លួន របស់លោកអ្នក ឬបុគ្គលណាដែលទទួលខុសត្រូវសម្រាប់ការថែទាំសុខភាពរបស់លោកអ្នក និងពីទីកន្លែងរបស់ លោកអ្នក ស្ថានភាពសុខភាពទូទៅ និងការបាត់បង់ជីវិតរបស់អ្នក។ ប្រសិនបើអ្នកមានវត្តមាន នោះមុននឹងប្រើប្រាស់ ឬផ្សព្វផ្សាយពីព័តិមានសុខភាពរបស់លោកអ្នក យើងនឹងផ្តល់ជាឱកាសមួយដល់លោកអ្នកដើម្បីធ្វើការបដិសេធចំពោះ ការប្រើប្រាស់ និងការផ្សព្វផ្សាយបែបនេះបាន។ នៅក្នុងកាលៈទេសៈ សង្គ្រោះបន្ទាន់ ឬក្នុងករណីអសមត្ថភាព យើងនឹងផ្សព្វផ្សាយព័តិមាន សុខភាពរបស់អ្នក ដោយអាស្រ័យលើការកំណត់មួយដែលប្រើប្រាស់ការវិនិច្ឆ័យប្រកប ដោយវិជ្ជាជីវៈរបស់យើង ដោយធ្វើការផ្សព្វផ្សាយតែព័តិមាន សុខភាពដែលមានភាពពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹង ការចូលរួមរបស់បុគ្គលក្នុងការថែទាំសុខភាពរបស់អ្នក។ យើងក៏នឹងប្រើប្រាស់ការវិនិច្ឆ័យ ប្រកបដោយវិជ្ជាជីវៈ និងបទពិសោធន៍ទាក់ទិននឹងការអនុវត្តទូទៅរបស់យើង ដើម្បីធ្វើជាសេចក្តីសន្និដ្ឋានដ៏សមហេតុផលមួយអំពីគុណប្រយោជន៍ ក្នុងការអនុញ្ញាតឱ្យបុគ្គលម្នាក់ មកទទួលយកវិជ្ជបញ្ជា ការផ្គត់ផ្គង់ផ្នែកពេទ្យ កាំរស្មីអ៊ិច និង ទម្រង់ផ្សេងៗនៃ ព័តិមានសុខភាពរបស់លោកអ្នក។

**ការធ្វើទីផ្សារសេវាកម្មដែលទាក់ទិននឹងសុខភាពៈ** យើងនឹងមិនប្រើប្រាស់ព័តិមានសុខភាពរបស់លោកអ្នកសម្រាប់ ទីផ្សារទំនាក់ទំនងដោយគ្មានសេចក្តីអនុញ្ញាតជាលាយល័ក្ខពីលោកអ្នកឡើយ។

**ការកំណត់ដោយច្បាប់ៈ** យើងអាចនឹងប្រើប្រាស់ ឬផ្សព្វផ្សាយព័តិមានសុខភាពរបស់លោកអ្នក ប្រសិនបើយើងត្រូវបាន តម្រូវដោយច្បាប់ ឱ្យធ្វើដូច្នោះ។

**ការបំពាន ឬភាពសោះអង្គើយៈ** យើងអាចនឹងផ្សព្វផ្សាយព័តិមានសុខភាពរបស់លោកអ្នកទៅកាន់អាជ្ញាធរ ប្រសិនបើយើងជឿជាក់ដោយ សមហេតុផលថាលោកអ្នកគឺជាជនរងគ្រោះនៃការបំពាន ភាពសោះអង្គើយ ឬអំពើហិង្សាក្នុង គ្រួសារ ឬក៏ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មផ្សេងទៀត។

**សន្តិសុខជាតិៈ** យើងអាចនឹងផ្សព្វផ្សាយទៅកាន់អាជ្ញាធរយោធានូវព័តិមានសុខភាពរបស់បុគ្គលិកយោធា តាមកាលៈទេសៈជាក់លាក់ណាមួយ។ យើងអាចផ្សព្វផ្សាយទៅកាន់មន្ត្រីសហព័ន្ធដែលមានការអនុញ្ញាតត្រឹមត្រូវ នូវព័តិមានសុខភាពដែលតម្រូវឱ្យធ្វើសម្រាប់ការស៊ើបអង្កេតស្របច្បាប់ ការស៊ើបអង្កេតប្រឆាំងការគំរាមកំហែង និងកិច្ចការពារសុវត្ថិភាពរបស់ជាតិដទៃផ្សេងទៀត។ យើងអាចនឹងផ្សព្វផ្សាយទៅកាន់ស្ថាប័នកែប្រែ ឬមន្ត្រីអនុវត្តច្បាប់ ដែលមានការដាក់ឃុំឃាំងស្របច្បាប់ពីព័តិមានសុខភាពដែលត្រូវបានការពារ របស់បុគ្គលដែលជាប់ឃុំឃាំង ឬរបស់អ្នកជំងឺ តាមកាលៈទេសៈជាក់លាក់ណាមួយ។

**ការរំលឹកពីការណាត់ជួបៈ** យើងអាចនឹងប្រើប្រាស់ ឬផ្សព្វផ្សាយព័តិមានសុខភាពរបស់អ្នក ដើម្បីផ្តល់ជាការរំលឹកពី ការណាត់ជួបដល់អ្នក (ដូចជា សារជាសម្លេង ប្រៃសណីយប័ត្រ សំបុត្រ)។

**សម្រាប់ការទាក់ទងដែលពាក់ព័ន្ធនឹងអ្នកជំងឺៈ** យើងអាចនឹងប្រើប្រាស់ ឬផ្សព្វផ្សាយពីព័តិមានសុខភាពរបស់អ្នក ដើម្បីផ្តល់ជាការទាក់ទងដែលពាក់ព័ន្ធនឹងអ្នកជំងឺ ដូចជា ការចេញវិជ្ជបញ្ជាតាមរយៈការហៅប្រព័ន្ធទូរស័ព្ទចូល ។ល។

**សិទ្ធិរបស់អ្នកជំងឺ**

**មធ្យោបាយៈ** អ្នកមានសិទ្ធិពិនិត្យមើល ឬទទួលបានអត្ថបទចតចម្លងពីព័តិមានសុខភាពរបស់លោកអ្នក ជាមួយករណីលើកលែងដែលមានកំណត់មួយចំនួន។ លោកអ្នកអាចនឹងស្នើរសុំឱ្យយើងផ្តល់ជាអត្ថបទចតចម្លង ក្នុងលក្ខណៈជាទម្រង់ណាមួយ ជាជាងទម្រង់ជាអត្ថបទចតចម្លង។ យើងនឹងប្រើប្រាស់ទម្រង់ដែលអ្នកស្នើរសុំ ក្នុងករណីយើងមិនអាចធ្វើដូច្នេះដោយសមហេតុផល។ អ្នកត្រូវតែធ្វើការស្នើរសុំជាលាយល័ក្ខអក្សរ ដើម្បីទទួលបាន

ព័ត៌មានសុខភាពរបស់អ្នក។ ប្រសិនបើអ្នកស្នើរសុំជាទម្រង់ផ្សេងទៀត នោះយើងអាចនឹង គិតថ្លៃទៅតាមតម្លៃ សម្រាប់ការផ្តល់ ព័ត៌មានសុខភាពរបស់លោកអ្នកនៅក្នុងទម្រង់នោះ។ អ្នកអាចទទួលបានទំរង់ បែបបទមួយដើម្បីស្នើ សុំទទួលបានព័ត៌មានដោយប្រើប្រាស់ព័ត៌មាន សម្រាប់ទំនាក់ទំនងដែលមាននៅខាងចុងបញ្ចប់នៃកំណត់សម្គាល់នេះ។

**គណនីយផ្សព្វផ្សាយៈ** លោកអ្នកមានសិទ្ធិទទួលតារាងករណីមួយចំនួនដែលយើង ឬដៃគូសហការធ្វើជំនួញរបស់យើង បានផ្សព្វផ្សាយព័ត៌មានសុខភាពរបស់អ្នកសម្រាប់គោលបំណងផ្សេងៗ ជាជាងការព្យាបាល ការបង់ថ្លៃប្រតិបត្តិការ ថែទាំសុខភាព និងសកម្មភាពផ្សេងៗមួយចំនួនទៀត សម្រាប់រយៈពេល៦ឆ្នាំចុងក្រោយ ឬសម្រាប់រយៈពេលខ្លី ទៅតាមអ្វីដែលអ្នកចង់គូសបញ្ជាក់។ ប្រសិនបើលោកអ្នកស្នើរសុំគណនីនេះលើសពីម្តងក្នុងរយៈពេល១២ខែនោះ យើងអាចនឹងគិតថ្លៃតាមតម្លៃសម្រាប់ជាការឆ្លើយតបនឹងការស្នើរសុំបន្ថែមទាំងនេះ។

**លក្ខខ័ណ្ឌៈ** អ្នកមានសិទ្ធិស្នើសុំឱ្យយើងដាក់លក្ខខ័ណ្ឌលើការប្រើប្រាស់ ឬការផ្សព្វផ្សាយពីព័ត៌មានសុខភាពរបស់ លោកអ្នក។ យើងមិនបានតម្រូវឱ្យយល់ស្របតាមលក្ខខ័ណ្ឌបន្ថែមទាំងនេះឡើយ (លើកលែងតែករណីដែល តម្រូវដោយច្បាប់ប្រាក់បង្កា (Recovery Act)សម្រាប់ប្រតិបត្តិការទឹកប្រាក់) ប៉ុន្តែប្រសិនបើយើង យល់ស្របតាមលក្ខខ័ណ្ឌនេះ យើងនឹងគោរពទៅតាមកិច្ចព្រមព្រៀង (លើកលែងក្នុងករណីបន្ទាន់)។

**ទំនាក់ទំនងផ្សេងទៀតៈ** លោកអ្នកមានសិទ្ធិស្នើសុំឱ្យយើងទាក់ទងជាមួយនឹងអ្នកទាក់ទិននឹងព័ត៌មានសុខភាពរបស់អ្នក តាមមធ្យោបាយផ្សេងទៀត ឬតាមរយៈទីតាំងផ្សេងទៀត។ អ្នកត្រូវតែធ្វើការស្នើសុំរបស់អ្នកជាលាយល័ក្ខអក្សរ។ សំណើររបស់អ្នកត្រូវតែគូសបញ្ជាក់ពីមធ្យោបាយ និងទីតាំងផ្សេងទៀត និងផ្តល់ជាការពន្យល់ប្រកបដោយ ភាពពេញចិត្តពីថាតើការបង់ថ្លៃគួរតែត្រូវដោះស្រាយតាមមធ្យោបាយ និងទីតាំង ផ្សេងទៀតដែលអ្នកស្នើសុំដោយរបៀបណា។

**ការធ្វើវិសោធនកម្មៈ** លោកអ្នកមានសិទ្ធិស្នើសុំឱ្យយើងធើ្វវិសោធនកម្មព័ត៌មានសុខភាពរបស់អ្នក។ សំណើររបស់អ្នកត្រូវតែស្ថិតក្នុងការសរសេរជាលាយល័ក្ខអក្សរ ហើយវាត្រូវតែពន្យល់ពីមូលហេតុដែលព័ត៌មាននេះត្រូវធ្វើ វិសោធនកម្ម។ យើងអាចនឹងបដិសេធលើសំណើរ របស់អ្នកក្នុងកាលៈទេសៈណាមួយ។

**កំណត់សម្គាល់អេឡិចត្រូនិចៈ** ប្រសិនបើលោកអ្នកទទួលបានកំណត់សម្គាល់នេះនៅលើគេហទំព័រ ឬតាមរយៈ ការបញ្ជូនសារអេឡិចត្រូនិចរបស់យើង នោះលោកអ្នកនឹងមានសិទ្ធិស្នើរសុំអត្ថបទថតចម្លងនៃកំណត់សម្គាល់នេះបាន។

**សំណួរ និងបណ្តឹង**

ប្រសិនលោកអ្នកត្រូវការព័ត៌មានបន្ថែមអំពីការអនុវត្តភាពជាឯកជន ឬមានសំណួរ ឬកង្វល់ផ្សេងៗ សូមទាក់ទង មកកាន់យើងខ្ញុំ។ បើអ្នកព្រួយបារម្ភថាយើងអាចនឹងរំលោភលើសិទ្ធិនៃឯកជនភាពរបស់អ្នក ឬអ្នកមិនយល់ស្រប នឹងសេចក្តីសម្រេចដែលយើងបានធ្វើឡើងទាក់ទិននឹងការទទួលបានព័ត៌មានសុខភាពរបស់អ្នក ឬជាការឆ្លើយតបនឹង សំណើរ ដែលអ្នកបានធ្វើដើម្បីធ្វើវិសោធនកម្ម ឬដាក់លក្ខខ័ណ្ឌលើការប្រើប្រាស់ ឬការផ្សព្វផ្សាយពីព័ត៌មានសុខភាព របស់អ្នក ឬក៏ចង់ឱ្យយើងទាក់ទងជាមួយអ្នកតាមមធ្យោបាយ ឬទីតាំងផ្សេងទៀត លោកអ្នកអាចប្តឹងមកកាន់យើងខ្ញុំ ដោយប្រើប្រាស់ព័ត៌មានសម្រាប់ទាក់ទងដែលមានចុះនៅចុងបញ្ចប់នៃកំណត់សម្គាល់នេះ។ ជាមួយគ្នានេះដែរ លោកអ្នកអាចដាក់ពាក្យបណ្តឹងជាលាយល័ក្ខអក្សរមកកាន់ក្រសួងសុខាភិបាល និងសេវាកម្មធនធានមនុស្សរបស់ សហរដ្ឋអាមេរិចបាន។ យើងក៏នឹងផ្តល់ឱ្យអ្នកនូវអាស័យដ្ឋានដើម្បីដាក់ពាក្យបណ្តឹងមកកាន់ក្រសួងសុខាភិបាល និងសេវាកម្មធនធានមនុស្សរបស់សហរដ្ឋអាមេរិច ក្រោយពីទទួលសំណើររបស់អ្នក។ យើងគាំទ្រសិទ្ធិនៃភាពជាឯកជន ស្តីពីព័ត៌មានសុខភាពរបស់អ្នក។ យើងនឹងមិនធ្វើឱ្យអ្នកទទួលរងគ្រោះតាមមធ្យោបាយណាមួយឡើយ ប្រសិនបើអ្នក ជ្រើសរើសដាក់ពាក្យបណ្តឹងមកកាន់យើងខ្ញុំ ឬទៅកាន់ក្រសួងសុខាភិបាល និងសេវាកម្មធនធានមនុស្សរបស់ សហរដ្ឋអាមេរិច។

**CONTACT INFORMATION**

**ព័ត៌មានទំនាក់ទំនង**

Ellen M. Hayenga

អ្នកសម្របសម្រួលផ្នែកសន្តិសុខ និងភាពឯកជន (Privacy and Security Coordinator)

សេវាកម្ម គ្រួសារ និងកូន (Family and Children Services)

950 W. Julian St.
San Jose, CA 95126
(408)292-9353
FAX: (408)287-3104
PrivacyCoordinator@fcservices.org